# ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា
CAMBODIA WATCHDOG COUNCIL INTERNATIONAL

ក្រុងគ្រីស្ទានសាន់ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៨

**សូមផ្ញើជូនលោកបណ្ឌិត ឌី ភារេត**
**ប្រធានស្តីទីនៃ គណៈកម្មាធិការព្រំដែនកម្ពុជាប្រទេសបារាំង និងពិភពលោក**

**លោកប្រធានស្តីទី និងសមាជិកសមាជិកា ជាទីគោរពដ៏ខ្ពង់ខ្ពស់**

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា មានកិត្តិយសសូមសរសេរលិខិតមួយច្បាប់នេះ ផ្ញើជូនចំពោះសមាជិកសមាជិកា នៃ គណៈកម្មាធិការព្រំដែនកម្ពុជាប្រទេសបារាំង និងពិភពលោក ខណៈពេលគណៈកម្មាធិការព្រំដែននេះ រៀបចំជ្រើសរើសថ្នាក់ដឹកនាំថ្មី នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៨ ដើម្បីបន្តបេសកកម្មរបស់ **លោក ស៊ាន ម៉េងសែ** ដែលបានទទួលមរណភាពកាលពីចុងខែមករា ឆ្នាំ២០១៨ កន្លងទៅ *«ក្នុងការការពារបូរភាពទឹកដីខ្មែរ ប្រឆាំងសន្ធិសញ្ញាព្រំដែនខុសច្បាប់ ផែនទីខុសច្បាប់ និងឯកសារខុសច្បាប់នានា ដែលធ្វើឡើងដោយរបប ហ៊ុន សែន សព្វថ្ងៃ»*។

ក្រុមប្រឹក្សារបស់យើងខ្ញុំ យល់ស្របជាមួយសមាជិកមួយចំនួននៃ គណៈកម្មាធិការព្រំដែន ដែលស្នើឡើងថា «សូមប្រគល់ភារកិច្ចទាំងអស់ជូនក្រុមការងារ អ្នកបច្ចេកទេស និងអ្នកជំនាញនៅប្រទេសបារាំង ចាត់ចែងទទួលខុសត្រូវរបស់ស្ថាប័ន» ផ្តល់ភាពងាយស្រួលក្នុងការយន្តការការងាររបស់ខ្លួន។

ដោយឡែកករណីមានសមាជិក ១នាក់ ឬ ២នាក់ ដែលចេញផ្សាយសេចក្តីប្រកាស ទិតៀនក្រុមការងារខ្លះ និង**លោកបណ្ឌិត ឌី ភារេត** នៅក្នុងគោលបំណងអ្វីផ្សេងនោះ វាមិនឆ្លុះបញ្ចាំងពីការពិតជាក់ស្តែង នៅចំពោះមុខសកម្មភាពការងាររបស់គណៈកម្មាធិការព្រំដែនកម្ពុជាទេ។

យើងខ្ញុំសូមស្នើយោបល់ដល់សមាជិកសមាជិកា គណៈកម្មាធិការព្រំដែនកម្ពុជា សូមផ្តល់ការគាំទ្រ **លោកបណ្ឌិត ឌី ភារេត** ជាបេក្ខភាពប្រធាន សម្រាប់អាណត្តិថ្មី។

ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

**ប្រធានក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា**

**ម៉ែន ណាត**

អសយដ្ឋាន ទីក្រុងគ្រីស្ទានសាន់ ប្រទេសន័រវេស /ប្រអប់សំបុត្រ #Senterveien 40, Apartment 112, 4790 Lillesand, NORWAY
Phone: (+47)90818257, E-mail: post: post@cwcicambodia.com /nathamonin@gmail.com /Web: www.cwcicambodia.com